## សំណង ៖ ឧក្រិដ្ឋជនអាចនឹងត្រូវបង់ប្រាក់ឲ្យអ្នក

នៅក្នុងរឿងក្តីបទឧក្រិដ្ឋ (និងរឿងក្តីបទល្មើសជាមជ្ឈិមខ្លះ) តុលាការអាចបញ្ជា ឲ្យឧក្រិដ្ឋជនជាប់ទោស បង់ប្រាក់ទៅឲ្យជនរងគ្រោះ សំរាប់ការខាតបង់របស់គេ។ ការនេះគេហៅថា ***សំណង***។

ក្រសួងការសាកល្បងខ្លួន នឹងសួរអ្នកបើសិនអ្នកចង់ឲ្យគេពន្យល់អំពីឧក្រិដ្ឋកម្ម ប៉ះពាល់ដល់អ្នកជាយ៉ាងណា។ វាគឺជាឱកាសសំរាប់អ្នកដើម្បី ៖

- ចុះរាយការខាតបង់ប្រាក់កាសរបស់អ្នក ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម, និង
- ទារសំណង។

តុលាការនឹងអានសេចក្តីថ្លែងការណ៍របស់អ្នក មុននឹងសំរេចទៅលើទណ្ឌកម្ម។

អ្នកមានសិទ្ធិដើម្បី ៖

- មានមុខនៅតុលាការ នៅពេលកាត់ទោសឧក្រិដ្ឋជន,
- ប្រាប់តុលាការ អំពីឧក្រិដ្ឋកម្មបានប៉ះពាល់ដល់អ្នកជាយ៉ាងណា, និង
- ថាទណ្ឌកម្មប្រភេទអ្វីដែលអ្នកជឿថានឹងល្អប្រពៃ រួមទាំងសំណង – ឬការបង់ប្រាក់កាសឲ្យអ្នក សំរាប់ការខាតបង់ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម។

ដើម្បីស្វែងយល់ថែមទៀតអំពីសិទ្ធិរបស់អ្នកចំពោះសំណង និងការកាត់ទោស សូមទាក់ទងយើង។

## អ្នកអាចនិយាយនៅពេលសវនាការ នៃការសាកល្បងខ្លួនរបស់អ្នកជាប់គុក

គ្រប់ទាំងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ អ្នកជាប់គុកមិនអាចដោះលែងដោយគ្មានសវនាការ នៃការសាកល្បងខ្លួនបានឡើយ។ អ្នកមានសិទ្ធិនិយាយ នៅពេលធ្វើសវនាការ។ អ្នកអាចប្រាប់គណៈសាកល្បងខ្លួន នូវមតិរបស់អ្នកអំពីពេលវេលា ដែលគួរតែដោះលែងអ្នកជាប់គុក។

*ចំណាំ ៖* បើឧក្រិដ្ឋជនមានអាយុក្រោម 18 ឆ្នាំ អនុវត្តតាមច្បាប់ពិសេស។ សូមទាក់ទងយើង បើអ្នកចង់និយាយទៅកាន់គណៈសាកល្បងខ្លួនយុវជន។

ដើម្បីស្វែងយល់ថែមទៀតអំពីសវនាការសាកល្បងខ្លួន សូមទាក់ទង ក្រសួងកែខៃខ្លួន និងស្តារលទ្ធភាព រដ្ឋកាលីហ្វ័រនីញ៉ា នៅឯ ៖ www.cdcr.ca.gov។



## កម្មវិធីផ្សេងទៀត សំរាប់ជួយអ្នក

មានកម្មវិធីគាំទ្រពិសេស និងក្រុមគាំពារជាច្រើន ដែលជួយជនរងគ្រោះ និងគ្រួសាររបស់គេ រួមទាំងជនរងគ្រោះនៃវិបត្តិការចាប់រំលោភ អំពើហិង្សាក្នុងគ្រួសារ និងការធ្វើបាបក្មេង។ សូមទាក់ទងយើង ដើម្បីរកកម្មវិធី ឬក្រុមគាំទ្រ។

## មណ្ឌលរបស់យើង

មណ្ឌលធនធានជនរងគ្រោះនៃបទឧក្រិដ្ឋ (Victims of Crime Resource Center) បានជួយជនរងគ្រោះនៃបទឧក្រិដ្ឋរាប់ពាន់នាក់ នៅពាសពេញរដ្ឋកាលីហ្វ័រនីញ៉ា តាំងពីឆ្នាំ 1984 មកម្ល៉េះ។ សេវារបស់យើងគឺឥតចេញថ្លៃឡើយ។ អ្នកជំនាញរបស់យើង មានព័ត៌មានថ្មីៗបំផុតក្នុងវិស័យនេះ។ យើងនៅទីនេះ ដើម្បីណែនាំអ្នក និងឆ្លើយសំណួរអ្វីមួយរបស់អ្នក។

សូមទាក់ទងយើង សំរាប់ព័ត៌មានបន្ថែម ឬអំពីការគាំទ្រសិទ្ធិរបស់អ្នក ៖

Victims of Crime Resource Center
University of the Pacific, McGeorge School of Law

- ទូរស័ព្ទ ៖ **1-800-VICTIMS** (1-800-842-8467)
- មើល ៖ www.1800VICTIMS.org

មណ្ឌលនេះគឺជាផែនការនៃ University of the Pacific,
McGeorge School of Law និង
California Emergency Management Agency
(CalEMA - www.oes.ca.gov)។

Cambodian

UNIVERSITY OF THE PACIFIC
McGeorge School of Law

# ជំនួយសំរាប់ជនរងគ្រោះឧក្រិដ្ឋកម្មក្នុងរដ្ឋកាលីហ្វ័រនីញ៉ា



ការជួយជនរងគ្រោះ និងគ្រួសាររបស់គេឲ្យស្គាល់សិទ្ធិរបស់គេ និងទទួលសេវា និងការគាំទ្រ

**Victims of Crime Resource Center**
(មណ្ឌលធនធានជនរងគ្រោះនៃបទឧក្រិដ្ឋ)
1-800-VICTIMS (1-800-842-8467)
www.1800VICTIMS.org

## សិទ្ធិរបស់ជនរងគ្រោះនៃបទឧក្រិដ្ឋ ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា

បើអ្នកជាជនរងគ្រោះនៃបទឧក្រិដ្ឋ អ្នកអាចនឹងត្រូវការនូវការគាំទ្រ ដើម្បីឲ្យស្រាកស្រាន្តពីក្រឹដ្ឋកម្ម។ ឧក្រិដ្ឋកម្មប្រហែលជាបានបណ្តាលឲ្យអ្នកខាតបង់ប្រាក់កាស ឬដំឡៃមេធាវី ឬមានបញ្ហាសុខភាព ឬបញ្ហាខាងផ្លូវចិត្ត។ ខិត្តប័ណ្ណនេះពន្យល់អំពីសិទ្ធិរបស់អ្នក និងសេវា ព្រមទាំងការគាំទ្រដែលមានសំរាប់អ្នក និងគ្រួសាររបស់អ្នក។

### អ្នកមានសិទ្ធិទៅលើ :

**ប្រាក់កាស។** តុលាការអាចបញ្ជាឲ្យឧក្រិដ្ឋជនបង់ប្រាក់សំរាប់ការខាតបង់របស់អ្នក ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម រួមទាំងប្រាក់បង់សំរាប់ :

- ការប្រឹក្សា
- បាត់បង់ប្រាក់ឈ្នួលធ្វើការ
- វិក្កយប័ត្រពេទ្យ សំរាប់ការរបួស, និង
- ដំឡៃបុណ្យសព និងការបូជា។

**ប្រាប់តុលាការអំពីការខាតបង់របស់អ្នក។** មុននឹងតុលាការសំរេចទៅលើទណ្ឌកម្មរបស់ឧក្រិដ្ឋជន អ្នកអាចប្រាប់តុលាការអំពីឧក្រិដ្ឋកម្មបានប៉ះពាល់ដល់ជីវិតរបស់អ្នកជាយ៉ាងណា។

**សុវត្ថិភាព និងការការពារ។** បើរូបអ្នក គ្រួសាររបស់អ្នក ឬសាក្សីណាមួយខ្លាចឧក្រិដ្ឋជន អ្នកអាចស្នើសុំតុលាការនូវបទបញ្ជាការពារ។

**ប្តឹងក្នុងតុលាការបណ្តឹងសំណងតិចតួច។** បើអ្នកមិនប្តឹងទារសំណាងលើសពី $10,000 ទេ អ្នកអាចប្តឹងក្នុងតុលាការបណ្តឹងសំណងតិចតួច។ អ្នកមិនបាច់ត្រូវការមេធាវី ក្នុងតុលាការនោះឡើយ។ ហើយតុលាការនិមួយៗមានទីប្រឹក្សាបណ្តឹងសំណងតិចតួច សំរាប់ជួយប្រជាជនជាមួយនឹងរឿងក្តីរបស់គេ។ ដើម្បីស្វែងយល់ថែមទៀត សូមទៅមើល :
www.courts.ca.gov/selfhelp-smallclaims.htm

> មានច្បាប់ពិសេសមួយហៅថា កំរងសិទ្ធិនៃជនរងគ្រោះ (ឬ ច្បាប់របស់ Marsy) គាំទ្រជនរងគ្រោះនៃបទឧក្រិដ្ឋ និងគ្រួសាររបស់គេ។
>
> វាជាគំនិតមួយដ៏ល្អដើម្បីអានច្បាប់នេះ ប្រយោជន៍ឲ្យអ្នកស្គាល់សិទ្ធិ ទាំងអស់របស់អ្នក។ អ្នកអាចផ្តិតច្បាប់នេះ និងទទួលបញ្ជីធនធាននៅឯ :
> www.oag.ca.gov/victimservices/marsy

**ប្តឹងក្នុងតុលាការស៊ីវិល។** អ្នកអាចប្តឹងប្តល់ប្រឆាំងនឹងឧក្រិដ្ឋជន ដើម្បីទារប្រាក់ ឬថ្លៃឈ្នួលមេធាវី។ បើម្ចាស់ទ្រព្យសម្បត្តិ ឬអង្គភាពរដ្ឋាភិបាល រួមចំណែកក្នុង ទោសពៃរ៍នៃបទឧក្រិដ្ឋ អ្នកក៏អាចប្តឹងគេបានដែរ។ *សារៈសំខាន់ !* វាមានពេលកំណត់ដាច់ខាត សំរាប់ការចាប់ផ្តើមរឿងក្តី ហើយច្បាប់តុលាការអាចជាស្មុគស្មាញ។ សូមឆាប់ពិគ្រោះជាមួយមេធាវីរបស់អ្នក បើអ្នកចង់ប្តឹង។ ដើម្បីរកមេធាវី សូមទូរស័ព្ទមកយើង ឬទូរស័ព្ទទៅ :

សេវាការបញ្ជូនទៅមេធាវី នៃស្មាក្តីនៅរដ្ឋកាលីហ្វ័រនីញ៉ា :
**1-866-442-2529** – *វាគឺជាលេខទូរស័ព្ទឥតចេញថ្លៃ !*



### ជំនួយ ដើម្បីទទួលប្រាក់ និងការគាំទ្រ

មានកម្មវិធី និងវិធី សំរាប់ជួយជនរងគ្រោះទទួលប្រាក់ ទទួលការគាំទ្រ និងការណែនាំ រួមមាន :

- កម្មវធីសងប្រាក់ឲ្យជនរងគ្រោះ (CalVCP)
- មណ្ឌលជំនួយជនរងគ្រោះ/សាក្សី (ខោនធីនិមួយៗមានមួយ)
- សំណង និងកម្មវិធី ហើយនិងអង្គការផ្សេងៗទៀត

### កម្មវិធីសងប្រាក់ឲ្យជនរងគ្រោះ

កម្មវិធីនេះអាចផ្តល់ប្រាក់ឲ្យជនរងគ្រោះម្នាក់ៗ ដល់ទៅ **$70,000** សំរាប់ការ ចំណាយជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម។ អ្នកអាចស្នើសុំប្រាក់សំរាប់ការចំណាយ ដែលមិនបានរ៉ាប់រងពេញលេញដោយក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក សំរាប់ថ្លៃការជំនុំជំរះ ឬទទួលកម្មវិធីផ្សេងៗទៀត រួមមាន :

- ការប្រឹក្សា, ថ្លៃពេទ្យ, និងថ្លៃសេវាធ្មេញ ឬប្រដាប់ប្រដា
- បាត់បង់ប្រាក់ឈ្នួលធ្វើការ, ប្រាក់ឧបត្ថម្ភមនុស្សក្នុងបន្ទុក, ឬថ្លៃមើលថែកូន បើអ្នកផ្តល់ការថែទាំពិការ ឬបានស្លាប់ដោយសារឧក្រិដ្ឋកម្ម
- ដំឡៃបុណ្យសព និងការបូជា
- ការហ្វឹកហ្វឺនការងារ ឬការហ្វឹកហ្វឺនសាថ្មី
- ប្រព័ន្ធសន្តិសុខផ្ទះ ឬការផ្លាស់ប្តូរផ្ទះ ឬឡានរបស់អ្នក ដែលអ្នកត្រូវការ ដោយសារឧក្រិដ្ឋកម្ម បានបណ្តាលឲ្យពិការ
- ការសំអាតកន្លែងឧក្រិដ្ឋកម្ម និងដំឡៃផ្លាស់លំនៅ
- ការ-រួមបង់ប្រាក់ ថ្លៃការធានារ៉ាប់រង

*សារៈសំខាន់ !* កម្មវិធីនេះមិនរ៉ាប់រងការខាតបង់*ទ្រព្យសម្បត្តិ*ទេ។

### អ្នកណាខ្លះ អាចទទួលការសងប្រាក់

អ្នកអាចស្នើសុំការសងប្រាក់ (ប្រាក់កាស) បើអ្នកមិនបានជួយបុព្វហេតុឧក្រិដ្ឋកម្ម និងមានចិត្តចង់រាយការណ៍ឧក្រិដ្ឋកម្ម ព្រមទាំងសហការជាមួយនគរបាល ហើយអ្នក :

- បានរបួស ដោយសារលក្ខណៈឧក្រិដ្ឋកម្ម,
- ជាមនុស្សក្នុងបន្ទុកនៃជនរងគ្រោះ,
- ជាអ្នកថែទាំជនរងគ្រោះ ដែលមានអាយុក្រោម 18 ឆ្នាំ,
- បងវិក្កយប័ត្រសំរាប់ជនណាម្នាក់ ដែលបានស្លាប់ដោយសារឧក្រិដ្ឋកម្ម, ឬ
- ជាញាតិសន្តាន ឬសមាជិកគ្រួសាររបស់ជនរងគ្រោះ ហើយអ្នកត្រូវការ នូវការថែទាំសុខភាព ការប្រឹក្សា ឬអ្នកបានខាតបង់ប្រាក់កាស ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម។

### របៀប ដើម្បីទទួលការសងប្រាក់

ដាក់ពាក្យសុំក្នុងពេល **1 ឆ្នាំ** នៃឧក្រិដ្ឋកម្ម (លុះត្រាតែអ្នកមានមូលហេតុល្អ សំរាប់ការដាក់ពាក្យសុំយឺតពេល)។ ដើម្បីដាក់ពាក្យសុំ សូមទាក់ទងផ្នែក ការសងប្រាក់ឲ្យជនរងគ្រោះ និងគណៈបណ្តឹងសំណងរដ្ឋាភិបាល (Victim Compensation and Government Claims Board) :

- ទូរស័ព្ទ : **1-800-777-9229** ឬ
- មើល : www.vcgbc.ca.gov

### របៀបផ្សេងទៀត ដើម្បីទទួលការសងប្រាក់

មានកម្មវិធីផ្សេងៗទៀតជាច្រើន ដែលផ្តល់ជំនួយប្រាក់កាសសំរាប់ជនរងគ្រោះ រួមមាន :

- ការសងប្រាក់ឲ្យកម្មករ
- ការធានារ៉ាប់រងពេលអត់ការងារ
- ជំនួយបណ្តោះអាសន្នសំរាប់គ្រួសារទ័លក្រ (TANF)
- កម្មវិធីភាពពិការរដ្ឋបាលសហព័ន្ធ និងរដ្ឋ
- Medi-Cal
- ការធានារ៉ាប់រងផ្ទះ ឬឡានរបស់អ្នក



### មណ្ឌលជំនួយជនរងគ្រោះ/សាក្សី

ខោនធីនិមួយៗមាន មណ្ឌលជំនួយជនរងគ្រោះ/សាក្សី (Victim/ Witness Assistance Center) មួយ។ មណ្ឌលទាំងនេះ ជួយជនរងគ្រោះ ដោះស្រាយបញ្ហាដែលបានបណ្តាលដោយសារឧក្រិដ្ឋកម្ម។

មណ្ឌលរបស់អ្នកនឹងជួយអ្នក :

- ដាក់ពាក្យសុំទៅ កម្មវិធីការសងប្រាក់ឲ្យជនរងគ្រោះ
- ត្រៀមខ្លួនស្រេចបាច់សំរាប់តុលាការ រួមទាំងការប្រាប់តុលាការអំពីឧក្រិដ្ឋកម្ម បានប៉ះពាល់ដល់អ្នកជាយ៉ាងណា និងស្នើតុលាការឲ្យដាក់បញ្ជាដល់ឧក្រិដ្ឋជន ឲ្យបង់ប្រាក់សំណងមកអ្នក
- ទទួលការបញ្ជូនទៅកម្មវិធីផ្សេងៗទៀត ដែលនឹងជួយអ្នក
- រៀបចំយានជំនិះ និងការមើលថែកូន នៅពេលអ្នកទៅតុលាការ
- ទទួលអាហារ ទីជំរក និងសំលៀកបំពាក់គ្រាអាសន្ន
- ទទួលបទបញ្ជាតុលាការ ដើម្បីការពារអ្នក និងគ្រួសាររបស់អ្នក
- និយាយបំភ្លឺអំពីអ្វីៗដែលបានកើតឡើងចំពោះនិយោជកវេជ្ជបណ្ឌិតរបស់អ្នក និងម្ចាស់បំណុល

### របៀបរក មណ្ឌលជំនួយជនរងគ្រោះ/សាក្សី របស់អ្នក

ដើម្បីរក មណ្ឌលជំនួយជនរងគ្រោះ/សាក្សី ក្នុងមូលដ្ឋានរបស់អ្នក :

- ទូរស័ព្ទមកយើង : **1-800-VICTIMS** (1-800-842-8467)
- មើលយើង : www.1800VICTIMS.org